unicef for every child

*សេចក្តីប្រកាសព័ត៌មាន*

# កុមារ និងយុវជនស្វែងរកមតិគាំទ្រសម្រាប់សិទ្ធិកុមារ និងសកម្មភាពឆ្លើយតបនឹងវិបត្តិអាកាសធាតុនៅក្នុងទិវាកុមារពិភពលោកនៅកម្ពុជា

ខេត្តក្រចេះ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣៖ កុមារ យុវជន អាជ្ញាធរ សិល្បករ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍មកពីគ្រប់វិស័យនៅកម្ពុជា មកជួបជុំគ្នានៅថ្ងៃនេះ ដើម្បីចាប់ផ្តើមពិធីអបអរសាទរទិវាកុមារពិភពលោកឆ្នាំ២០២៣ រយៈពេលបីថ្ងៃ ដែលប្រារព្ធជាផ្លូវការនៅថ្ងៃទី២០ ខែវិច្ឆិកា។ នៅឆ្នាំនេះ យូនីសេហ្វប្រចាំកម្ពុជា នឹងបង្កើនសំឡេងរបស់កុមារ និងយុវជន ក្នុងនាមជាអ្នកស្វែងរកមតិគាំទ្រសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។

លោកបណ្ឌិត វីល ផាកស៍ ប្រធានយូនីសេហ្វប្រចាំកម្ពុជាបានមានប្រសាសន៍នៅក្នុងពិធីបើកព្រឹត្តិការណ៍ទិវាកុមារពិភពលោកថា៖ "យើងកំពុងស្ថិតនៅខេត្តក្រចេះ ដើម្បីអបអរសាទរចំពោះសក្តានុពល និងកិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីគាំទ្រកុមារ និងយុវជននៅកម្ពុជា។ "ប៉ុន្តែថ្ងៃនេះក៏រំលឹកយើងអំពីបញ្ហាប្រឈមដ៏ពិបាកៗដែលកុមារកំពុងជួបប្រទះ ដូចជាការរងគ្រោះពីកំណើននៃជម្លោះ និងគ្រោះមហន្តរាយបរិស្ថាននៅទូទាំងពិភពលោកផងដែរ។"

លោកបានបន្តទៀតថា ខណៈដែលយើងកំពុងប្រារព្ធពិធីនេះក្នុងពេលកុមារស្ថិតក្នុងស្ថានភាពលំបាកទាំងអស់នេះក៏ដោយ ខ្ញុំសូមចែករំលែកនូវសារនៃក្តីសង្ឃឹម។ ព្រឹត្តិការណ៍នេះបានផ្តល់ដល់យើងនូវឱកាសដើម្បីបង្កើតភាពជាដៃគូថ្មីៗជាមួយបណ្តាញយុវជន សិល្បករ និងអាជ្ញាធរមូលដ្ឋានដែលបានមករួមកម្លាំងគ្នា ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ។ តាមរយៈការចូលរួម និងបរិយាបន្នយុវជន យើងទាំងអស់គ្នាទទួលបានផលប្រយោជន៍ពីសក្តានុពលមិនគួរឱ្យជឿរបស់ពួកគេ ក្នុងនាមជាអ្នកបង្កើតការផ្លាស់ប្តូរវិជ្ជមាន សម្រាប់អភិវឌ្ឍសង្គម។"

ភាពជាដៃគូជាមួយពិធីបុណ្យភូមិមានជើង ដែលជាពិធីវប្បធម៌ដ៏មានប្រជាប្រិយមួយ ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ឱកាសចូលរួមដល់កុមារ និងយុវជននៅខេត្តក្រចេះ ដែលជាខេត្តមួយនៅភាគឦសាននៃប្រទេស។ យុវជនស្ម័គ្រចិត្តជាង ២០០នាក់បានទទួលឱកាស ដើម្បីសហការរៀបចំ និងត្រួត

ពិនិត្យព្រឹត្តិការណ៍នេះ ដែលនឹងកំពុងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី១៩ ខែវិច្ឆិកា នៅជុំវិញបរិវេណវត្តរការកណ្តាល ដោយរួមមានការដឹកនាំសកម្មភាពស្តីពីសិទ្ធិកុមារ។

កញ្ញា រិទ្ធី លំអរពេជ្យ ស្ថាបនិកក្រុមយុវជនភ្លើងគុបដែលរៀបចំពិធីបុណ្យភូមិបានមានប្រសាសន៍ថា៖ "ពិធីបុណ្យភូមិមានជើងបានសហការជាមួយយូនីសេហ្វ ដើម្បីអបអរសាទរទិវាកុមារពិភពលោក។ ជាផ្នែកមួយនៃព្រឹត្តិការណ៍នេះ យើងបានបណ្តុះបណ្តាលយុវជនស្ម័គ្រចិត្ត ដើម្បីផ្តល់ឲ្យពួកគេនូវចំណេះដឹង និងជំនាញអំពីធុរកិច្ច ការធ្វើការងារជាក្រុម និងស្វ័យយល់ដឹងពីខ្លួនឯងសម្រាប់ការដាក់ពាក្យស្នើសុំអាហារូបករណ៍។ ក្នុងភាពជាដៃគូជាមួយយូនីសេហ្វ យើងក៏នឹងរៀបចំសិក្ខាសាលានានាអំពី សុខភាពផ្លូវចិត្ត អាហារូបត្ថម្ភ និងការប្រែប្រួលអាកាសធាតុ សម្រាប់អ្នកស្ម័គ្រចិត្ត ដែលកំពុងរៀបចំព្រឹត្តិការណ៍នេះផងដែរ។"

យុវជនក៏នឹងដឹកនាំសកម្មភាពដាំដើមឈើ សម្អាតប្លាស្ទិក និងសំណល់ និងចូលរួមនៅក្នុងការប្រកួតប្រជែងសម្តែងតន្ត្រី និងការសម្តែងសិល្បៈផងដែរ។ នៅថ្ងៃអាទិត្យ ទី១៩ ខែវិច្ឆិកា សិល្បករខ្មែរដ៏ល្បីល្បាញមួយចំនួនរួមមាន វណ្ណដា វណ្ណថាន់ សុភា ចម្រើន កេសរ និង សាយ នឹងមកសម្តែងនៅលើឆាកនៅមាត់ទន្លេមេគង្គ។

យុវជនផាន់ណា អាយុ២១ឆ្នាំ សិស្សស្ម័គ្រចិត្តនៅភូមិយូនីសេហ្វ ជាកន្លែងផ្តល់សិក្ខាសាលា និងល្បែងកម្សាន្តសម្រាប់យុវជន និងកុមារនៅថ្ងៃទី១៨ និងទី១៩ ខែវិច្ឆិកា បានមានប្រសាសន៍ថា៖ "ក្នុងនាមជាយុវជនស្ម័គ្រចិត្ត ខ្ញុំកំពុងរៀនសូត្របានយ៉ាងច្រើនទាក់ទងនឹងការរៀបចំព្រឹត្តិការណ៍ផ្សេងៗ រហូតដល់ការដឹកនាំវគ្គនានាអំពីសិទ្ធិកុមារ របៀបធ្វើសកម្មភាពរក្សាបរិស្ថានរបស់យើង និងកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកផងដែរ។ វាជារឿងអស្ចារ្យណាស់ ដែលខ្ញុំមានឲ្យកាសធ្វើសេចក្តីសម្រេចអំពីសកម្មភាពនានា និងអនុវត្តសកម្មភាពទាំងនោះ ដែលយើងគិតថាមានសារប្រយោជន៍ និងគួរជាទីរីករាយ។ តាមរយៈល្បែងកម្សាន្ត និងសិល្បៈ យើងអាចបង្កការចូលរួមរបស់មិត្តភក្តិរបស់យើងកាន់តែច្រើន ដើម្បីធ្វើសកម្មភាពលើកកម្ពស់សិទ្ធិកុមារ និងឆ្លើយតបនឹងវិបត្តិអាកាសធាតុ។"

លោកជំទាវ ឯកឧត្តមរដ្ឋលេខាធិការមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិបាលរងខេត្តក្រចេះ ឯកឧត្តមឯកអគ្គរាជទូតប្រទេសគុយវេត និងមន្ត្រីមកពីស្ថានទូតបារាំង ក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) នៃប្រទេសអូស្ត្រាលី ព្រមទាំងអ្នកតំណាងមកពីអង្គការមិនមែនរដ្ឋាភិបាល បានចូលរួមនៅក្នុងពិធីបើកទិវានេះនៅសាលមហោស្រពខេត្តក្រចេះ។

បណ្ឌិត វីល ផាកស៍ បានបន្ថែមទៀតថា៖ "ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅ ប្រទេសកម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្តក្នុងការពង្រឹងសិទ្ធិកុមារ។ បញ្ហាប្រឈមនៅតែមាននៅក្នុងប្រទេស ហើយយូនីសេហ្វមានការប្តេជ្ញាចិត្តពេញលេញក្នុងការដោះស្រាយបញ្ហាទាំងនេះ ដោយលើកកម្ពស់សិទ្ធិ និងពង្រឹងសុខុមាលភាពរបស់កុមារដែលងាយរងគ្រោះបំផុត។"

ទិវាកុមារពិភពលោក គឺជាទិវាសកម្មភាពជាសកលសម្រាប់កុមារ ដឹកនាំដោយកុមារ។ ទិវាកុមារពិភពលោករំលឹកអំពីការអនុម័តអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ហើយប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅឆ្នាំ១៩៩២។ យូនីសេហ្វ និងដៃគូកំពុងអំពាវនាវឲ្យមានពិភពលោករួមគ្នាមួយ ដែលគ្មានការទុកកុមារណាម្នាក់ចោល ដែលសិទ្ធិរបស់ពួកគេត្រូវបានទទួលការការពារ និងសំឡេងរបស់ពួកគេត្រូវបានគាំទ្រដើម្បីឈានទៅសម្រេចបាននូវអនាគតរបស់ខ្លួន។

###

**អំពីយូនីសេហ្វ**

យូនីសេហ្វបំពេញការងារនៅតាមតំបន់ ដែលជួបការលំបាកបំផុតមួយចំនួននៅក្នុងពិភពលោក ដើម្បីគាំទ្រដល់កុមារដែលជួបការលំបាកជាងគេនៅក្នុងពិភពលោក។ ជាមួយវត្តមាននៅក្នុងប្រទេស និងដែនដីជាង ១៩០ យើងធ្វើការដើម្បីកុមារគ្រប់រូបនៅគ្រប់ទិសទី ដើម្បីកសាងពិភពលោកកាន់តែប្រសើរសម្រាប់គ្រប់គ្នា។

សម្រាប់ព័ត៌មានបន្ថែមអំពីយូនីសេហ្វ និងការងាររបស់យូនីសេហ្វក្នុងប្រទេសកម្ពុជា សូមចូលមើលវេបសាយ៖ https://www.unicef.org/cambodia

សូមតាមដានព័ត៌មានអំពីយូនីសេហ្វកម្ពុជាតាមរយៈ Facebook | Twitter | YouTube | Instagram | Linkedin | Threads | TikTok

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖**

លោក អាគ្រ្វាន បូណូ ប្រធានផ្នែកទំនាក់ទំនង យូនីសេហ្វកម្ពុជា
ទូរសព្ទ ៖ +៨៥៥ ២៣២៦០២០៤ សារអេឡិចត្រូនិក៖ hbonnaud@unicef.org
លោក មាស ប៊ុនលី មន្ត្រីជំនាញផ្នែកទំនាក់ទំនង យូនីសេហ្វកម្ពុជា
ទូសព្ទ ៖ +៨៥៥ ៩២២៤២៦២ សារអេឡិចត្រូនិក៖ bmeas@unicef.org